SIPAR

*Douangkhe Bounyavong - Sikko Milakong*

# សំពង្ស និងកូនទាទាំងប្រាំ



រឿងដំបូង១



Original story by ***Outhine BOUNYAVONG***
Adapted to picture book by ***Douangkhe BOUNYAVONG***
Design and Illustrations works by ***Douangkhe BOUNYAVONG*** and ***Sikko MILAKONG***
Text and pictures copyright © ***Dokked Publishing Co., Ltd, 2005***

**បោះពុម្ពផ្សាយជាភាសាខ្មែរ © គ្រឹះស្ថានបោះពុម្ពផ្សាយ SIPAR, 2010**

*រាល់ការចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ទោះបីជាតាមរបៀបណាក៏ដោយ*
*បើគ្មានការយល់ព្រមពីអង្គការ SIPAR គឺខុសច្បាប់ និងត្រូវមានទោស។*



# សំពង្ស និងកូនទាទាំងប្រាំ

អ្នកនិពន្ធ : Douangkhe Bounyavong - អ្នកគូររូប : Sikko Milakong

គ្រឹះស្ថានបោះពុម្ពផ្សាយ SIPAR

សំពង្សមានកូនទាទាំងអស់ប្រាំមួយ ប៉ុន្តែងាប់អស់មួយ ហើយនៅសល់ប្រាំ។ ម្តាយរបស់គេបានទិញកូនទាទាំងនោះពីផ្សារព្រោះរាល់ព្រឹក សំពង្សចូលចិត្តញាំពងទា។







ពេលកូនទាទាំងប្រាំមានអាយុបានពីរអាទិត្យ ពួកវាអាចហែលទឹកបានហើយ។ រៀងរាល់ថ្ងៃ មុនពេលទៅសាលារៀន សំពង្សនាំពួកវាទៅកាន់ថ្លុកតូចមួយ នៅក្នុងទីធ្លាផ្ទះ។



ពេលចេញពីរៀន ឬចុងសប្តាហ៍ សំពង្សកាន់ចបជីក ចេញទៅរក
ជន្លេននៅក្នុងដី និងនៅក្រោមថ្មៗ



ពេលសំពង្សរកបានជន្លេនម្តងៗ
កូនទាទាំងប្រាំតែងប្រញាយ
ដណ្តើមគ្នាស៊ីៗ



ជារឿយៗ ពេលជីករកជន្លេន សំពង្សបារម្ភណាស់ ព្រោះកូនទា ទាំងអស់តែងសំរុកចូលមករកចបជីករបស់គេ។ គេខ្លាចចបជីកប៉ះត្រូវពួកវា។

ពេលកូនទាឃើញសំពង្សដើរទៅរៀន ពួកវារត់តាមពីក្រោយ។ ពួកវាគ្រវីកន្ទុយតូចៗរបស់ខ្លួន ដើម្បីបង្ហាញថា ពួកវារីករាយ និងដើម្បីទារចំណី។

ផ្ទះរបស់សំពង្សស្ថិតនៅជាប់មាត់ផ្លូវ។ បើកូនទាចេញពីទីធ្លាសំពង្ស ត្រូវនាំពួកវាចូលទៅវិញ ដើម្បីកុំឱ្យម៉ូតូ ឬកង់កិនពួកវា។





សំពង្សស្រលាញ់កូនទារបស់គេណាស់ ហើយពួកវាក៏ស្រលាញ់គេវិញដែរ។ ពួកគេជាមិត្តល្អនឹងគ្នា។ ម្តាយរបស់សំពង្សក៏ស្រលាញ់កូនទាទាំងនេះដែរ ហើយគាត់ពេញចិត្តរបៀបដែលកូនប្រុសគាត់ថែរក្សាកូនទាទាំងប្រាំនេះណាស់។



គាត់ចូលចិត្តមើលកូនប្រុសគាត់ឱ្យចំណីកូនទា។
វាធ្វើឱ្យគាត់មានអារម្មណ៍រីករាយ ពោរពេញទៅ
ដោយមោទនភាព និងភាពកក់ក្ដៅ។






ដើម្បីកុំឱ្យបាត់បង់កូនទាទៀត សំពង្សយកឫស្សីមកធ្វើរបងព័ទ្ធជុំវិញ
ផ្ទះ ដោយធ្វើទ្វារមួយផង។ ជួនកាល អ្នកផ្ទះភ្លេចបិទទ្វាររបង។
ជួនកាល សំពង្សខ្លួនឯងក៏ភ្លេចបិទដែរ។

នៅពេលកូនទាទាំងនេះមានអាយុ៤អាទិត្យ សំពង្សបាត់បង់កូនទាមួយទៀត។ នៅសល់តែកូនទាបួនទេ។ ពេលឃើញថា កូនសត្វមិនមែនសុទ្ធតែអាចរស់នៅរហូតដល់ធំបាន សំពង្សពិបាកចិត្តជាខ្លាំង។

រឿងនេះកើតឡើងនៅថ្ងៃអាទិត្យមួយ...





សំពង្សចេញទៅជាមួយពួកម៉ាក ពេញមួយថ្ងៃ។ ពេលគេត្រលប់មកផ្ទះវិញ មានមនុស្សឈរនៅមុខផ្ទះរបស់គេ។ ម្ដាយរបស់គេ និងពូវ៉ាង ដែលជាអ្នកជិតខាង កំពុងតែនិយាយគ្នាអំពីរឿងកូនទា។

«វាជាកូនទារបស់សំពង្យ។»
«វាងាប់បាត់ទៅហើយ។»
«កូនទានេះដើរឆ្លងផ្លូវ។»





ពូវ៉ាងលើកកូនទាឡើង។

គ្រាន់តែឃើញកូនទារបស់ខ្លួនភ្លាម សំពង្សរត់សំដៅទៅគាត់ ហើយស្រែកយំ។

«អ្នកណាសម្លាប់កូនទាខ្ញុំ? ពុទ្ធោអើយ! កូនទារបស់ខ្ញុំងាប់ហើយ!»

ពូវ៉ាងពន្យល់ថា :

«ពេលនោះ វារត់កាត់ផ្លូវ ចំពេលពូជិះកង់មកដល់ ហើយពូអត់បានឃើញវា»។

«ខ្ញុំចង់ឱ្យវារស់ឡើងវិញ។ ពូត្រូវតែធ្វើឱ្យវារស់ឡើងវិញ!»



ម្ដាយសំពង្សនិយាយថា : «មិនអីទេកូន។ ម៉ែនឹងទិញមួយទៀតឱ្យឯង។ ប៉ុន្តែ ឯងត្រូវមើលថែពួកវាឱ្យបានល្អ។ ហើយឯងទៅណាបាត់ពេញមួយថ្ងៃ?»

ពូវ៉ាងពិបាកចិត្តជាខ្លាំងចំពោះរឿងកូនទារបស់សំពង្ស។

គាត់សំរេចចិត្តថា នឹងសងកូនទាមួយទៅឱ្យសំពង្សវិញ។

ពូវ៉ាងនិយាយថា : «ពូនឹងយកកូនទារបស់កូនប្រុសពូ ឱ្យទៅឯងវិញ។ វាក៏មានអាយុប្រហែលជាប្អូនអាទិត្យដែរ។ តស់ ទៅជាមួយពូ»។

ពេលពួកគេទៅដល់ផ្ទះរបស់ពូវ៉ាង គាត់ក៏ទៅចាប់កូនទាពីក្នុងទ្រុង។







សុងជាត ដែលជាកូនប្រុសពូវ៉ាង ឃើញឪពុកយកកូនទារបស់ខ្លួនចេញទៅៗ គេស្រែកឡើងថា : «ពុកយកកូនទាខ្ញុំទៅណា?»



ពូវ៉ាងនិយាយប្រាប់កូនគាត់ថា : «ពុកឱ្យវាទៅសំពងស្រុះៗ បន្តិចទៀតយើងនឹងមានកូនទាច្រើន ព្រោះពងទាយើងជិតញាស់ហើយ»ៗ សុងជាតយំ : «អត់ទេ! អត់ទេពុក! វាជាកូនទាខ្ញុំទេ!»







ពូវ៉ាងឱ្យកូនទានោះទៅសំពង្ស។
គាត់យកកង់របស់គាត់ឌុបសំពង្ស
ត្រលប់ទៅផ្ទះវិញ។
ពេលចាកចេញពីផ្ទះពូវ៉ាង
សំពង្សឃើញសុងដាតយំ
មិនទាន់បាត់នៅឡើយ។ សំពង្ស
មិនសប្បាយចិត្តទេ។ គេមានអារម្មណ៍ថា
គេបានលួចរបស់ពីអ្នកដទៃ។

ពេលមកដល់ផ្ទះវិញ សំពង្សឱ្យចំណីដល់កូនទាទាំងអស់។ កូនទាទាំងបួនរបស់គេស៊ីចំណីអស់គ្មានសល់ ប៉ុន្តែកូនទាថ្មីខ្លាច មិនហ៊ានចូលស៊ីជាមួយឡើយ។ វានៅតែឯងដាច់ឆ្ងាយពីគេ។ សំពង្សត្រូវឱ្យចំណីវាមួយចានផ្សេងដាច់ដោយឡែក។ កូនទាថ្មីពិបាកចិត្ត ហើយស្ងៀមស្ងាត់។ សំពង្សគិតដល់សុងដាត។

«គេប្រាកដជាស្រលាញ់កូនទារបស់គេដែរ។ តើខ្ញុំគួរធ្វើយ៉ាងម៉េច?»







«ខុសមកពីខ្ញុំ ដែលមិនបានមើលថែពួកវា នៅថ្ងៃនោះ។ ខ្ញុំបែរជាដើរលេងជាមួយពួកម៉ាក។ ខ្ញុំបានយកកូនទារបស់សុងដាត ហើយពេលនេះ គេគ្មានកូនទាមួយសោះ។ ចំណែកខ្ញុំវិញ ខ្ញុំមានប្រាំ។ បែបនេះមិនយុត្តិធម៌ទេ។»

សំពង្សគិតរឿងនេះ ពេញមួយថ្ងៃ។

ល្ងាចនោះ គេក៏ទៅកាន់ផ្ទះពូវ៉ាង។



«នេះណែសុងផាត! កូនទានេះជារបស់ឯងៗ
ខ្ញុំនៅសល់ប្អូនទៀតៗ»



សុងផាតតបវិញថា : «អរគុណ» ។

សំពង្សញញឹម ដើរត្រលប់ទៅផ្ទះ ទាំងសប្បាយចិត្ត បន្ទាប់ពី បានប្រគល់កូនទាទៅឱ្យសុងជាតវិញ។






**ការថ្លែងអំណរគុណ**

យើងខ្ញុំសូមអរគុណចំពោះ **Clotilde EAV** ដែលបានចូលរួមសហការ ដើម្បីបោះពុម្ពសៀវភៅនេះ ។
សៀវភៅនេះបានទទួលការឧបត្ថម្ភពី **Fondation Equilibre** ។

La publication de ce livre est rendue possible grâce au financement de la *Fondation Equilibre*.

អ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ : **ហុក សុទ្ធិ**
អ្នកសំរបសំរួលបោះពុម្ពផ្សាយ : **ហួត សុជាតា**
អ្នកបោះពុម្ពផ្សាយ : **ម៉េង សុមនា**
អ្នកទទួលខុសត្រូវក្រាភិច : **ជ្រឹម ហុកស្រ៊ិន**
អ្នករចនាទំព័រ : **ប៉ែន សំបូរណ៍**
អ្នកពិនិត្យអត្ថបទ : **ក្រុមបោះពុម្ពផ្សាយនៃអង្គការ** SIPAR

© Éditions SIPAR 2010

*ផ្ទះលេខ១ ផ្លូវ21, ប្រអប់សំបុត្រ31, ភ្នំពេញ - កម្ពុជា*
*ទូរស័ព្ទ : 855-23 216 001* / *siparedition@online.com.kh*

បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព Digital Advertising

*Supported by*

EUROPEAN COMMISSION

រឿងដំបូងៗ

សំពង្សចូលចិត្តញាំពងទារាល់ព្រឹក។ ម្ដាយរបស់គេបានទិញកូនទាប្រាំមួយដើម្បីឱ្យគេចិញ្ចឹមយកស៊ុត។ ប៉ុន្តែ ដោយសារតែការធ្វេសប្រហែសរបស់ខ្លួន គេត្រូវបាត់បង់កូនទាពីរ។ កំហុសឆ្គងនេះបានបង្រៀនសំពង្សឱ្យស្គាល់អ្វីដែលហៅថាកើតទុក្ខ ឱ្យចេះអភ័យទោស និងឱ្យយល់ពីអ្នកដទៃផងដែរ។

SIPAR

9 789995 054670